BMI0172

# សម្ភាសន៍ជាមួយឈ្មោះ វ៉ាន់ ទាវ ភេទស្រី អាយុ៩១ឆ្នាំ
# មុខងារនៅសម័យខ្មែរក្រហមៈ កងចល័តនៅអាងត្រពាំងថ្ម
# សព្វថ្ងៃរស់នៅភូមិប៉ោយព្រីង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
# សម្ភាសន៍ដោយៈ ហ៊ិន សុផានី
# ០០:៣៨:២០
# ២៥ទំព័រ

ផានី : ថ្ងៃនឹង ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ។ ខ្ញុំឈ្មោះ ផានី ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចុះមកនេះ គ្រាន់ចង់សាក់សួរមីងពីប្រវត្តិរបស់មីងដែលបានឆ្លងកាត់កាលពីសម័យខ្មែរក្រហម ។ ហើយរឿងរ៉ាវទាំងអស់នឹង ខ្ញុំសុំយកទៅចុះក្នុងទស្សនាវដ្ដីក៏ដូចជាសម្រាប់អ្នកសិក្សាស្រាវជ្រាវផ្សេងៗ យកទៅសិក្សាស្រាវជ្រាវ ហើយក៏សម្រាប់ការសិក្សាទាំងអស់នេះ គឺទុកឲ្យក្មេងជំនាន់ក្រោយបានដឹង បានរៀន បានសូត្រ នេះជាសៀវភៅដែលពួកខ្ញុំចង់ចុះ ។ ជាដំបូងខ្ញុំសុំអនុញ្ញាតិមីងថតជាសម្លេងបានទេ ហើយខ្ញុំថតជារូបបានទេ?

ទាវ : បាន ។

ផានី : មីងមានឈ្មោះអីដែរ?

ទាវ : ខ្ញុំឈ្មោះ វ៉ាន់ ទាវ ។

ផានី : ឆ្នាំនឹងអាយុប៉ុន្មានហើយ?

ទាវ : ឆ្នាំនឹង៩១ហើយ ។

ផានី : មីងមានស្រុកកំណើតនៅណា?

ទាវ : ប៉ោយព្រីង ។

ផានី : ចឹងរាល់ថ្ងៃមីងរស់នៅប៉ោយព្រីង ស្រុកកំណើតនៅនឹងដែរ?

ទាវ : ចា៎!

ផានី : ចឹងនៅភូមិប៉ោយព្រីង ឃុំអីដែរ?

ទាវ : ឃុំព្រះនេត្រព្រះ ។

ធានី ៖ ស្រុកអីគេ?

ទាវ ៖ ស្រុកព្រះនេត្រព្រះ ។

ធានី ៖ ខេត្ត?

ទាវ ៖ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឪពុកមីងឈ្មោះអីគេ?

ទាវ ៖ ឪពុកខ្ញុំស្លាប់អស់ហើយ ។

ធានី ៖ ឈ្មោះអីគេឪពុក?

ទាវ ៖ ឈ្មោះ ភ៉ាន់ ខាន់ ។

ធានី ៖ គាត់ស្លាប់ពេលណា?

ទាវ ៖ គាត់ស្លាប់យូរហើយ បាន៤-៥-៦-៧ឆ្នាំ ដឹងស្លាប់ឆ្នាំណា ។

ធានី ៖ ដោយសារអីគេ?

ទាវ ៖ គាត់ជម្ងឺ ។

ធានី ៖ ចុះម្ដាយឈ្មោះអីគេ?

ទាវ ៖ ម្ដាយខ្ញុំឈ្មោះ មុយ ប៊ិន ។

ធានី ៖ គាត់នៅរស់ទេ?

ទាវ ៖ ទេ! គាត់ស្លាប់ដែរ ។

ធានី ៖ ស្លាប់ពេលណា?

ទាវ ៖ ស្លាប់មុនឪពុកខ្ញុំ ស្លាប់ជាង១០ឆ្នាំ ១២-១៣ឆ្នាំ ហ៎!១៧ឆ្នាំហើយ ម៉ែខ្ញុំ ។

ធានី ៖ ដោយសារឈឺ?

ទាវ ៖ ចា៎!

ធានី ៖ មីងមានបងប្អូនប៉ុន្មាននាក់?

ទាវ ៖ បងប្អូន៩នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ទាវ ៖ ប្រុសតែ១ទេ ។

ធានី ៖ ស្រី៨ ប្រុស១ នៅរស់ទាំងអស់ទេ?

ទាវ ៖ ស្លាប់អស់ហើយ ស្លាប់ស្រីអស់២ ។

ធានី ៖ ស្រី២?

ទាវ ៈ ចាំ! ១ស្លាប់សម័យអាពត ។

ធានី ៈ ដោយសារអីដែរ?

ទាវ ៈ គាត់កូនង៉ា ស្លាប់ ទាស់ស្លាប់ ។

ធានី ៈ ចុះមួយទៀត?

ទាវ ៈ មួយទៀតស្លាប់ឥឡូវៗនឹង ស្លាប់បាន២ឆ្នាំហើយ ។

ធានី ៈ ដោយសារអីដែរ?

ទាវ ៈ កើតមហារីកស្បូន ។

ធានី ៈ មីងរៀបគ្រួសារនៅឆ្នាំប៉ុន្មាន?

ទាវ ៈ ៨៣ កូនខ្ញុំអាយុបាន២៥ឆ្នាំហើយ ។

ធានី ៈ គ្រួសារមីងឈ្មោះអីគេ?

ទាវ ៈ ឈ្មោះ ហង្ស សឹម ។

ធានី ៈ មានកូនប៉ុន្មាននាក់?

ទាវ ៈ កូន៥នាក់ ។

ធានី ៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ទាវ ៈ ស្រី២ ប្រុស៣ ។

ធានី ៈ មីងបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ទាវ ៈ ខ្ញុំអត់បានរៀនទេ ។

ធានី ៈ ចឹងតាំងពីតូចមកមីងធ្វើអីខ្លះទៅ?

ទាវ ៈ ពីតូចមកខ្ញុំឃ្វាលតែគោនៅក្រោម ។

ធានី ៈ រហូតដល់ពេលណា?

ទាវ ៈ ដល់ពេលខ្មែរក្រហមចូលនេះ ខ្ញុំដើរចល័តរហូត អត់បានរៀនទេ ។

ធានី ៈ ចឹងមីងអត់បានទៅរៀនទៅអីទេ នៅឃ្វាលគោ?

ទាវ ៈ ចាំ!

ធានី ៈ នៅក្នុងភូមិយើងកាលនឹងមានហេតុការណ៍អីកើតឡើងដែរអត់ទេ ពេលនឹង ពេលដែល មីងនៅក្មេងៗ នៅឃ្វាលគោ គេមានហៅទៅព្រៃចូលអីៗមានទេ?

ទាវ ៈ អត់ទេ ។

ធានី ៈ មីងអត់ដឹង ឬក៏អត់មាន?

ទាវ ៖ អត់មានទេ ។

ធានី ៖ នៅភូមិនឹង អត់មានអ្នកណាចូលបដិវត្ត ចូលអីអត់មាន?

ទាវ ៖ ទេ! បដិវត្ត មានត្រឹមតែខ្មែរក្រហមចូលទៅ ខ្ញុំអត់នៅភូមិនេះទេ ខ្ញុំជម្លៀសទៅនៅដក់ពរ ។

ធានី ៖ អ្នកភូមិយើងទៅនៅដក់ពរទាំងអស់គ្នា?

ទាវ ៖ ចាំ! មុនដំបូងខ្មែរក្រហមចូលមុនដំបូង គេជម្លៀសឲ្យទៅនៅស្រែៈៗបានប៉ុន្មានខែបាន៣ខែ ៨ខែគេឲ្យមកនោដក់ពរវិញ បាននៅជាប់រហូត ។

ធានី ៖ ម៉េចទៀតមីង?

ទាវ ៖ ដល់ពេលខ្ញុំនៅភូមិស៊ីតែបបររហូតពេកទៅ ខ្ញុំនៅក្មេងនៅតូច អាយុទើប១៥ ខ្ញុំសុំគេទៅចល័ត ។

ធានី ៖ ម៉េចទៀតមីង?

ទាវ ៖ ទៅខ្ញុំលើកចល័តទំនប់ព្រៃមាន់នោះ ក្រវាត់ព្រៃមាន់នោះរួចគេឲ្យមកភូមិវិញ ។ ដល់មកភូមិវិញ ខ្ញុំនៅខ្ញុំអត់ចេះហូបបបរ ខ្ញុំសុំគេទៅចល័តទៀត ហូបតែបបរខ្ញុំអត់ចេះហូបទេ ។ ខ្ញុំសុំទៅចល័តទៀត គេយកទៅលើកនៅត្រពាំងថ្មនឹង ។

ធានី ៖ ចឹងមីងទៅចល័តនឹង គេឲ្យហូបបាយ?

ទាវ ៖ ហូបបាយ ប៉ុនហូបបាយវាស់ចាន កាលនៅភូមិហូបបបរខ្ញុំអត់ចេះហូបបបរទេ ខ្ញុំសុំទៅនៅចល័ត ។

ធានី ៖ ចឹងពេលទៅត្រពាំងថ្ម ហូបបាយរហូត និយាយទៅឲ្យតែមីងទៅកងចល័ត មីងអត់ដែលបាន ហូបបាយ?

ទាវ ៖ អត់ដែលហូបបបរ ។

ធានី ៖ អត់ដែលហូបបបរសោះ?

ទាវ ៖ អត់ទេ ។

ធានី ៖ ចឹងនៅកងចល័តហូបបាយដែរ?

ទាវ ៖ ហូបបាយ ប៉ុនយើងវាស់ម៉ារបប ។

ធានី ៖ ប៉ុន្មាន?

ទាវ ៖ ប៉ុនហូបទៅវាអត់ឆ្អែតដែលណា ប៉ុនយើងបានហូបបាយ គ្រាន់ខ្ញុំទៅលើកចល័តនៅ ចល័តត្រពាំងថ្ម ខ្ញុំលើកខ្សែត្រៀមទី១កន្លែងស្ពានរាបនោះ ទឹកមុជ មានបានរាល់ថ្ងៃខ្វះ ។ បើសិនជាទៅខ្សែត្រៀមទី២ក៏អត់សូវមានទឹកមុជដែរ អត់ ។

ធានី ៖ ខ្សែត្រៀមទី២នៅណា កូនខ្ញែងនឹង?

ទាវ ៖ ត្រពាំងថ្មនឹង ប៉ុនខ្សែត្រៀមទី១នៅខាងស្ពានរាប ដល់ទី២ទៅខាងកើតនោះ ។

ធានី ៖ ចុះស្ពានរាបនឹង នៅត្រពាំងថ្មដែរ ប៉ុន្តែនៅខាងវិញ?

ទាវ ៖ នៅខាងលិចៗទី៣ ខាងកើតមកទៀតទី២ ខាងកើតបន្ទាប់ពីត្រពាំងថ្មគេទៅ ភូមិគេទី១ ។

ធានី ៖ ចុះស្ពានរាបនឹងនៅទី១?

ទាវ ៖ ទី៣ ស្ពានទី៣ ។

ធានី ៖ ស្ពានទី៣ ឬក៏ខ្សែត្រៀមទី៣?

ទាវ ៖ ស្ពានទី៣លើករួច មកលើកទី១មកដាក់ចល័តនារីៗផ្សេង ។

ធានី ៖ មីងប្រាប់ថាខ្សែត្រៀម?

ទាវ ៖ ចាំ!

ធានី ៖ ព្រោះធម្មតាយើងធ្វើកងចល័តចឹង ទៅលើកទំនប់មានខ្សែត្រៀមហើយណា?

ទាវ ៖ ចាំ!

ធានី ៖ វាមាន៣ខ្សែត្រៀម ត្រូវទេមីងនិយាយមិញ?

ទាវ ៖ ចាំ!

ធានី ៖ ចឹងខ្សែត្រៀមទី១នៅស្ពានរាប ឬខ្សែត្រៀមទី៣នៅស្ពានរាប?

ទាវ ៖ ខ្សែត្រៀមទី៣នៅស្ពានរាប ។

ធានី ៖ ចឹងខ្សែត្រៀមទី១នៅ?

ទាវ ៖ ត្រពាំងថ្ម ។

ធានី ៖ ទី១នៅត្រពាំងថ្មខាងណា?

ទាវ ៖ ត្រពាំងថ្មខាងកើត ។

ធានី ៖ ចុះខ្សែត្រៀមទី២?

ទាវ ៖ ខាងលិច ។ ដល់ទី៣បាននៅខាងលិចទៀត ។

ធានី ៖ ចឹងទី១ខាងកើត ទី២ខាងលិច?

ទាវ ៖ ចាំ!

ធានី : ដល់ពេលទី៣?

ទាវ : ខ្ញុំទៅលើកខាង ដល់ពេលទី៣នោះគេដាក់ធំៗនារី ដល់ពេលនោះខ្ញុំទៅលើកក្រវាត់ទៀត រួច អានោះហើយទៅនោះអាក្រវាត់អានោះត្រពាំងថ្មកូនខ្វែងទៅលើកនោះទៀត ។ ដល់ទៅ លើកនៅនោះរៀងយ៉ាប់តិច លើកខាងនោះម៉ាអាទិត្យអីបានដួតទឹកម្តង ។

ធានី : ម៉េចចឹង?

ទាវ : អត់មានទឹក ។

ធានី : ម៉េចបានអត់មានទឹក?

ទាវ : អត់មានទឹកទេ ដូចថាត្រពាំងណាមានមួយចេះនាំគ្នាដួតទាល់តែអស់ ។ អត់ទឹកហូបគេជីកឲ្យ ហូប ជីកទៅក៏កងណាហូបមិនគ្រាន់ទេ ។

ធានី : ម៉េចចឹង?

ទាវ : ចុះទឹកចែកគ្នា ដាក់បំពង់ចែកគ្នា ។ ខ្លះក៏រួចលើក៣ម៉ែត្រគីបរួចចេះទៅ នាំគ្នាទៅដងទៅស៊ីង ណាំតាវណា ឆ្ងាយណាស់ ។

ធានី : ចឹងមីងអត់មានទឹកហូបហើយទៅដងទឹក ។ ចឹងម៉ាថ្ងៃគេឲ្យលើកប៉ុន្មានម៉ែត្រគីប?

ទាវ : ៣ ។

ធានី : ម៉ាថ្ងៃ៣ម៉ែត្រគីប សម្រាប់កងមីង?

ទាវ : ចាំ!

ធានី : កងនឹងហៅកងកុមារ?

ទាវ : កងកុមារ ។

ធានី : ចុះមានកងមនុស្សចាស់ដែរអត់?

ទាវ : មានតើ ។

ធានី : កងមនុស្សចាស់កងម៉េច?

ទាវ : កងមនុស្សចាស់លើក៣ម៉ែត្រដូចគ្នា ៣ម៉ែត្រកន្លះ ៣ម៉ែត្រគីប ប៉ុនកុមារយើងលើករួចក៏ បានយើងលើកមិនរួច យើងលើកយប់ទៀត ។ ហើយអ្នកខ្វាក់មាន់ចេះទៅ ដាក់ម៉ាក្រុមអ្នក ងងឹតមាន់ទៅ ។

ធានី : ចឹងធ្វើម៉េចបើងងឹតមើលអត់ឃើញ?

ទាវ : មើលអត់ឃើញ តែយប់ងងឹតហើយ គេដាក់ម៉ាកងគេ ក្រុមគេងងឹតមាន់ទៅ ។

ធានី ៖ ចង់និយាយថាដាក់កង់ងនឹតមាន់ចឹង កុមារគាត់ធ្វើយ៉ាងម៉េច បើយប់ឡើងមើលមិនឃើញ ហើយកាប់យ៉ាងម៉េច?

ទាវ ៖ មានអ្នកភ្លឺម្នាក់អ្នកកាប់ទៅ អ្នកងនឹតមាន់ដាក់តគ្នាចេះទៅ លើកបង្គីរតគ្នាលើកឡើងលើ ចង្ក្អូរទៅឡើងលើ ។

ធានី ៖ តែមីងធ្វើពេលយប់ដែរ?

ទាវ ៖ យប់ដល់ម៉ោង១១ បានឲ្យដេក ។

ធានី ៖ ៣ម៉ែត្រគីបដល់ម៉ោង១១?

ទាវ ៖ ចាំ!

ធានី ៖ ដាទូទៅដឹងថាកំណត់៣ម៉ែត្រគីប?

ទាវ ៖ ៣ម៉ែត្រគីប ។

ធានី ៖ ត្រូវធ្វើឲ្យហើយ ៣ម៉ែត្រគីប៤ជ្រុង?

ទាវ ៖ ៤ជ្រុង ។

ធានី ៖ ជីកចុះក្រោម?

ទាវ ៖ ជីកចុះក្រោមកន្លះម៉ែត្រ ៣ម៉ែត្រការ៉េ ។

ធានី ៖ ចឹង៣ម៉ែត្រជុំវិញហើយ កន្លះម៉ែត្រចុះក្រោមទៀត?

ទាវ ៖ ចាំៗ ។

ធានី ៖ ជំរៅកន្លះម៉ែត្រ?

ទាវ ៖ ចាំ!

ធានី ៖ ចុះមីងដូចថា ពេលមីងនៅត្រពាំងថ្មនឹង គឺហូបបាយម៉ាកូនចានចង្កឹះ?

ទាវ ៖ ចាំ! ភ្លឺឡើងចែកគ្នាទៅ ។

ធានី ៖ ហូបអីម៉េចដែរ ការហូបល្អអត់?

ទាវ ៖ មិនមានទេ គ្មានអីហូបទេ ជួនកាលស្ករដែនយើងចែកគ្នាម្នាក់ម៉ាដែនទៅ ជួនកាលទឹកប្រហុក យើងដាំទឹកប្រហុកដាក់លាយស្ករទៅ ។

ធានី ៖ ទឹកប្រហុក?

ទាវ ៖ ចាំ!

ធានី ៖ ដាក់ទឹកប្រហុកនឹងវាមិនពិបាក ព្រោះយើងមើលគ្រាន់យើងនៅប៉ុននឹងមាន?

ទាវ ៖ ចាំ!

ធានី ៖ សត្វរុយឡើងពេញទាំងនោះហើយ ចុះទម្រាំសម័យនោះទៀត?

ទាវ ៖ អត់ដឹង មិនដឹងធ្វើម៉េច បើអត់ទៅហើយ ។

ធានី ៖ ហូប ចុះមានគេឈឺ មានអី?

ទាវ ៖ ឈឺ ខ្លះក៏មានជីវិតបានមកវិញទៅ ខ្លះក៏ស្លាប់នៅនោះទៅ ។

ធានី ៖ ទោះជានេះក៏ដោយ?

ទាវ ៖ ចាំ!

ធានី ៖ ត្រូវតែហូប?

ទាវ ៖ ត្រូវតែហូប ។

ធានី ៖ ដល់ពេលឈឺអីចឹង មានពេទ្យមានអីគេជួយមើល?

ទាវ ៖ មានថ្នាំពេទ្យគេបើកឲ្យលេប ប៉ុនលេបវាមិនបាត់ ។

ធានី ៖ ចុះមីងដូចថាក្មេងៗភាគច្រើនដែលធ្វើការឲ្យមីង ភាគច្រើននៅរស់ទាំងអស់គ្នាទេ?

ទាវ ៖ ទេ! ភូមិនេះស្លាប់អស់ហើយ ។

ធានី ៖ អស់រលីង?

ទាវ ៖ ចាំ!

ធានី ៖ ទៅជាមួយមីងប៉ុន្មាននាក់កាលនឹង?

ទាវ ៖ ទៅច្រើនដែល៤-១០ ស្លាប់កាលគេបាញ់ត្រពាំងថ្ម ។ កាលដែលយួនទៅលើកទំនប់ ដែល យួនចូលហើយ ក៏ខ្មែរក្រហមបាញ់នោះ ។

ធានី ៖ ម៉េចចឹងមីង ក្រែងត្រពាំងថ្មធ្វើហើយតើ ពេលយួន?

ទាវ ៖ ធ្វើហើយ តែជួសជុលវា ។

ធានី ៖ មីងទៅជួសជុល?

ទាវ ៖ ខ្ញុំអត់ទៅ តែប្អូនខ្ញុំទៅ ។ ប្អូនខ្ញុំមីងពៅគេៗរាប់ទៅជំនួសខ្ញុំ ឲ្យខ្ញុំរកស៊ីចិញ្ចឹមម៉ែ ។

ធានី ៖ ចឹងនៅភូមិមីងប៉ុន្មាននាក់ ដែលទៅចាំទេ?

ទាវ ៖ ទេ! ខ្ញុំមិនសូវចាំទេ វាយូរគ្រាន់ហើយ ។

ធានី ៖ មីងរកនឹកមើលប្រហែលជាប៉ុន្មាននាក់ទៅ ដែលទៅជាមួយមីង?

ទាវ ៖ ប៉ុនវាស្លាប់ហើយ ហៀប ហាន ណាត អាសែ អាហឿ ១២-១៣នាក់ដែរ ស្លាប់ ហើយ ។

ធានី ៖ ២នាក់ ហើយប្អូនមីងម្នាក់ដែរ?

ទាវ ៖ ចាំ! ប្អូនស្រីខ្ញុំអត់ស្លាប់ ។

ធានី ៖ ប្អូនស្រីឈ្មោះអីគេ?

ទាវ ៖ ឈ្មោះ វ៉ាន់ សន ត្រូវរបួស ក្រៅពីនឹងស្លាប់អស់ហើយ ។

ធានី ៖ នៅគាត់តែម្នាក់ដែលនៅរស់ ក្រៅពីនឹង?

ទាវ ៖ នៅបានប៉ុន្មាននាក់ ទៅគ្នាជាង២០នាក់ ស្លាប់អស់១៦នាក់ ។

ធានី ៖ ចឹង២០ប៉ុន្មាននាក់មីងរកនឹកមើល?

ទាវ ៖ ក្រែលដែរ ទាំងនារីទាំងអីច្រើនដែរ ភូមិយើង ។

ធានី ៖ ដែលថាទៅជួសជុលទំនប់នឹង?

ទាវ ៖ ជួសជុលទំនប់នឹង សម័យយួនចូលនេះតើ ។

ធានី ៖ ចង់និយាយថាតាំងពីមីងធ្វើនៅទំនប់នឹងរហូតមក តើមីងធ្វើនៅទំនប់នឹងរហូតមក តើមីងមើលឃើញអ្នកដែលនៅភូមិមីងទៅជាមួយមីង មានស្លាប់ច្រើនអត់ដែលទៅធ្វើការនៅនឹងហើយស្លាប់អីចឹង?

ទាវ ៖ ទៅធ្វើការនៅនឹងអត់ស្លាប់ទេ ទើបនឹងស្លាប់ដែលយួនចូលហើយ ក៏ទៅលើកជួសជុល ខ្មែរក្រហមលោកបាញ់ស្លាប់ ។

ធានី ៖ ប៉ុន្មាននាក់?

ទាវ ៖ ថាស្លាប់ប៉ុន្មាននាក់ទេ ។

ធានី ៖ ចុះម៉េចបានទៅលើកជួសជុល ក្រែងខ្មែរក្រហមអ្នកឲ្យធ្វើឬមួយក៏ខាង?

ទាវ ៖ ខាងយើងនេះឯង ឲ្យទៅជួសជុលនោះៗ ខ្មែរក្រហមលបបាញ់ ។ ស្លាប់ភូមិខ្ញុំច្រើនដែរ ។

ធានី ៖ ឆ្នាំប៉ុន្មានមីងចាំទេ?

ទាវ ៖ ខ្ញុំអត់ចាំទេ អារឿងឆ្នាំប៉ុន្មានទេ ។ ខ្ញុំមិនបានជាចាំទុកផង ។

ធានី ៖ ឥឡូវៗយើងដែរអត់ ឬមួយក៏?

ទាវ ៖ ហ៎! យូរគ្រាន់ហើយ ២០ឆ្នាំជាងហើយ ។

ធានី ៖ ឆ្នាំពីវៀតណាមចូលមកដំបូងៗ?

ទាវ ៖ ចាំ!

ធានី ៖ ម៉េចបានវៀតណាមឲ្យទៅជួសជុលទំនប់ធ្វើអី?

ទាវ ៖ ខូច ។

ធានី ៖ ខូចយ៉ាងម៉េច?

ទាវ ៖ ខូចឲ្យទៅជួសជុលអាទំនប់យើងក្រវ៉ាត់ល្អាងស្រែ ដល់ទៅជួសជុលទៅ យប់ឡើងដេកទៅ លេងទៅខ្មែរក្រហមគេមកលបបាញ់ស្លាប់អស់ប៉ុន្មាន១៦នាក់ ។

ធានី ៖ តែភូមិមីងទេ?

ទាវ ៖ ចាំ! តែភូមិខ្ញុំ១៦នាក់ ។

ធានី ៖ បានន័យថាមានអ្នកផ្សេងក្រៅពីភូមិមីងទៀត?

ទាវ ៖ ក្រៅពីភូមិខ្ញុំ កាលនោះងាប់អស់ប៉ុន្មាននាក់ទេ ២០នាក់ជាង ។ ប៉ុន្តែភូមិខ្ញុំ១៦នាក់ ទាំងចាស់ទាំងក្មេង ។

ធានី ៖ ពេលមីងនៅធ្វើការនៅអាងទំនប់នឹងដូចថាមីងជួបរឿងអីប្លែកៗ ហើយរបៀបថាអ្នកបាត់ខ្លួន នៅកងជាមួយមីង ឬក៏ប្រជាជនថ្មី?

ទាវ ៖ អត់ទេ ខ្ញុំអត់ដែលជួបទេ តែកាលនោះខ្ញុំនៅតូចផង ។

ធានី ៖ កាលមីងនៅកងចល័តរបស់មីងមានតែក្រុមចាស់ៗទេ ឬមានអ្នកថ្មីមកដែរ?

ទាវ ៖ នៅតើ ។

ធានី ៖ នៅដែរ?

ទាវ ៖ នៅ ។

ធានី ៖ កុមារ ចាស់ៗដូចមីង?

ទាវ ៖ ចាំ!

ធានី ៖ កុមារថ្មីៗចូលរួមជាមួយកងមីងដែរ ឬអត់ទេ?

ទាវ ៖ មានតើ មានចាស់ មានថ្មី ចូលលាយគ្នា តែច្រើនមកពីខាងភ្នំពេញ មកពីខាង ។

ធានី ៖ ប៉ុនធ្វើបានដូចយើងដែរ?

ទាវ ៖ ច្រើនឈឺ មកពីខាងនោះឯង ច្រើនឈឺ ខ្លះទៅស្លាប់នឹងពស់ចឹក ។

ធានី ៖ ស្លាប់ពស់ចឹកម៉េច?

ទាវ ៖ ពស់ចឹកស្លាប់ នៅជុំខ្ញុំមាននារីម្នាក់ស្អាតណាស់ ពស់ចឹកស្លាប់ ។

ធានី ៖ គាត់មកពីភ្នំពេញដែរ?

ទាវ ៖ ចាំ! នៅជាមួយក្រុមខ្ញុំនឹងឯង ។

ធានី ៖ គាត់ធ្វើអីគេ បានពស់ចឹកស្លាប់?

ទាវ ៖ លើកដីយប់ទៅ ក៏ពស់ចឹកនៅអន្លង់យើងលើក ស្លាប់ភ្លាមៗក៏កប់ចោលក្នុងព្រៃនឹងទៅ ។

ធានី ៖ កប់ចោលក្នុងព្រៃ ឬកប់ចោលនៅកន្លែងណា?

ទាវ ៖ កប់ចោលក្នុងព្រៃនឹង កន្លែងលើក ។

ធានី ៖ ចឹងកន្លែងលើកនឹង?

ទាវ ៖ ចាំ!

ធានី ៖ ចឹងកន្លែងលើកនឹងកាលមុនព្រៃ ហើយម៉េច?

ទាវ ៖ ព្រៃ ។

ធានី ៖ ព្រៃស្ងួមស្ងាំង?

ទាវ ៖ ចាំ!

ធានី ៖ នៅកន្លែងត្រពាំងថ្មនឹង?

ទាវ ៖ ចាំ! ព្រៃតើ ។

ធានី ៖ ចឹងដែលថាកប់ចោលៗក្នុងព្រៃ នៅលើកទំនប់នឹងទេ?

ទាវ ៖ ទេ! កប់នៅវាលព្រៃចោលចេះ ។

ធានី ៖ នៅក្បែរទំនប់នឹង?

ទាវ ៖ ចាំ!

ធានី ៖ តែមិនមែននៅទំនប់នឹង?

ទាវ ៖ អត់ទេ បើត្រូវគេកប់នៅទំនប់នឹងទៅ ក៏គេយកទៅកប់នឹងទំនប់នឹងទៅ ។

ធានី ៖ ធ្វើម៉េចបានដឹងថាយើងត្រូវយកទៅកប់នៅទំនប់នឹង?

ទាវ ៖ ទេ! យប់ឡើងក៏មិនហ៊ានមើលទេ ។

ធានី ៖ ប៉ុន្តែបានដឹង?

ទាវ ៖ គ្រាន់តែលួចមើលឃើញតែគេសែងអីមកដាក់ទៅ ក៏យើងលួចមើលគេទៅ ។

ធានី ៖ ហើយលួចមើលឃើញ គេធ្វើម៉េចខ្លះ?

ទាវ ៖ ឃើញគេយកមកកប់នឹងបាតទំនប់ ដឹងគេកប់ណាណៃ យើងមិនបានដឹង ទាល់តែឃើញ យប់លួចមើលទៅ ។

ធានី ៖ ពេលដែលយើងកំពុងតែធ្វើការនឹង?

ទាវ ៖ ចាំ! ក៏លួចមើលទៅ ។ មិនហ៊ានមើលទេ តែយើងឃើញ យើងឈរមើលអី គេវ៉ៃចោល ហើយ ។

ធានី ៖ លួចមើលយ៉ាងម៉េច មីងឃើញគេសែងមកពីណា?

ទាវ ៖ អត់ដឹងគេសែងមកពីណា បើយើងនៅធ្វើការ គ្រាន់តែឃើញគេដាក់មកយើងមើលទៅម៉ាក្រឡេកទៅក៏យើងឈប់ហ៊ានមើលទៅ ។

ធានី ៖ ឃើញតែមួយនឹងទេ ឬឃើញផ្សេងទៀត ដែលធ្លាប់មានអ្នកផ្សេងទៀតឃើញមីងធ្វើចឹងដែរ?

ទាវ ៖ ខ្ញុំមិនសូវឃើញទេ ។ ខ្លះទៅ ខ្លះលើកជិតស្ពាន អ្នកនៅជិតស្ពានបានគេឃើញ ។

ធានី ៖ ហេតុអីបានអ្នកនៅជិតស្ពានបានគេឃើញ?

ទាវ ៖ ស្ពាននេះគេច្រើនយកមនុស្សយកមកកល់ដាក់ធ្វើស្ពាន ។

ធានី ៖ ម៉េចចឹង?

ទាវ ៖ មិនដឹងរឿងគេគ្រាន់ថាខ្ញុំនៅតូច មិនដឹងរឿងគេផង ។

ធានី ៖ ម៉េចបានគេឲ្យតែកន្លែងធ្វើស្ពានគេយកមនុស្សមកដាក់?

ទាវ ៖ មិនដឹងដែរ ។

ធានី ៖ មានប៉ុន្មាននាក់ទៅ?

ទាវ ៖ អត់ដឹងទេ កន្លែងស្ពានខ្ញុំអត់បាននៅទេ ។

ធានី ៖ ចុះម៉េចបានមីងដឹងថាមានគេយកដាក់កន្លែងស្ពាន?

ទាវ ៖ ទេ! ដូចថាយប់គេសែង ហើយយើងនិយាយទៅដូចនៅឆ្ងាយៗឃើញគេសែងទៅគេសែង ពីក្រោមស្ពានទៅយើងដឹងថាគេដាក់នៅកន្លែងស្ពាន ហើយយើងអត់បានឈរមើលគេទេ ។

ធានី ៖ ឃើញច្រើនដងទេ?

ទាវ ៖ ទេ! ឃើញម្តងនឹងឯង តែខ្ញុំលើករួចនោះ ខ្ញុំទៅខ្សែត្រៀមទៀតទៅ បើគេអ្នកធ្វើស្ពាននៅប្រចាំនោះបានគេផង សុទ្ធតែមានប្រចាំការណ៍នៅស្ពាន ធ្វើយូរ តែខ្ញុំគ្រាន់ចល័តខាងលើក្រវាត់ល្អងប៉ុននោះឯង ។

ធានី ៖ ចឹងជាទូទៅ ឲ្យតែអ្នកធ្វើការនៅស្ពាននឹង គឺដឹងថាបាត់ខ្លួន?

ទាវ ៖ ដឹង ។

ធានី ៖ មិនមែនទេ ដឹងថាបាត់ខ្លួន ដឹងថាមានគេយកមកកប់នៅកន្លែងហ្នឹង?

ទាវ ៖ ចា៎! បើអ្នកធ្វើការនៅស្ពានប្រចាំការណ៍នៅស្ពានបានដឹង ។

ធានី ៖ ចុះឮថាអ្នកវាស់ឲ្យយើងមើលទំនប់ មើលប្រឡាយអីដឹងទេ អ្នកអស់នឹងអាចដឹងទេ?

ទាវ ៖ អស់នឹងអាចដឹង ។

ធានី ៖ ហើយមីងស្គាល់អ្នកអស់នឹងអត់?

ទាវ ៖ អត់ទេ ។

ធានី ៖ ចុះមីងស្គាល់អ្នកណាជាមេកងរបស់មីង?

ទាវ ៖ អត់ស្គាល់ទេ ខ្ញុំស្គាល់អ្នកនៅកំបោរប៉ុនគាត់ស្លាប់ហើយ ។

ធានី ៖ គាត់ឈ្មោះអីគេ?

ទាវ ៖ ដឹងឈ្មោះអីសម័យកាលនោះឈ្មោះ និ
ប៉ុនសព្វថ្ងៃកាលនោះឈ្មោះគាត់កាលនោះគាត់ប្រែ ឈ្មោះសម័យអាពត ។

ធានី ៖ គាត់មកពីណាវិញ អ្នកបាត់ដំបង?

ទាវ ៖ អត់ទេ អ្នកកំបោរ ប៉ុនមិនដឹងថាគាត់ជម្លៀសមកពីណា អត់ដឹងទេ ។ ប៉ុនខ្ញុំដឹងថាគាត់នៅកំបោរមេកងខ្ញុំ ។

ធានី ៖ មេកងមីង?

ទាវ ៖ ចា៎!

ធានី ៖ មេកងស្រី?

ទាវ ៖ ប្រុស ។

ធានី ៖ ហើយគាត់ប្រាប់ថានៅកំបោរ?

ទាវ ៖ កំបោរយើង ។

ធានី ៖ កំបោរព្រះនេត្រព្រះយើង?

ទាវ ៖ ចា៎!

ធានី ៖ ចឹងមេកងរបស់មីងគេហៅមេកងចល័ត ឬមេកងអីគេ?

ទាវ ៖ មេកងចល័ត ។

ធានី ៖ ចល័តអីគេ ចល័តរបស់មីងហៅចល័តអីគេ?

ទាវ ៖ ចល័តជំនួយទៅពីភូមិមិនបានហៅចល័តតំបន់ទេ ថាចល័តភូមិជំនួយទៅ ។

ធានី ៖ ចឹងមីងនៅបានម៉ារយៈៗ?

ទាវ ៖ ចា៎!

ធានី ៖ ចឹងមីងទៅទំនប់នឹងរហូតដល់ប៉ុន្មានឆ្នាំ?

ទាវ ៖ ទៅជាងម៉ាឆ្នាំ ។

ធានី ៖ ទាំងខែប្រាំង ខែវស្សា?

ទាវ ៖ ទៅខែវស្សា ខែប្រាំង ។

ធានី ៖ ខែប្រាំង ខែវស្សាអត់ទៅទេ?

ទាវ ៖ ខែវស្សាអត់ទៅ ខែវស្សាលើកអត់កើតទេ ទឹក ។

ធានី ៖ ចុះខែវស្សាអត់ធ្វើទេ គេធ្វើខែប្រាំង?

ទាវ ៖ ធ្វើខែប្រាំង ។

ធានី ៖ ចឹងទំនប់នឹងធ្វើតែខែប្រាំង?

ទាវ ៖ ចា៎!

ធានី ៖ ទំនប់នឹងធ្វើហើយពេលណា?

ទាវ ៖ ទំនប់នឹង ហើយកាលឆ្នាំប៉ុន្មានទេ ខ្ញុំភ្លេចដែរហើយ កាលខ្ញុំនៅតូចដែរ ។

ធានី ៖ មីងរកនឹកមើលដូចមីងធ្វើបានប៉ុន្មានឆ្នាំ បានទំនប់នឹងរួច?

ទាវ ៖ មិនទាន់មានធ្វើរួចណា ទៅម៉ាខែរ្យត្រៀមចេះទៅយើងរួចបាន២-៣ខែ គេដកយើងយកមក ភូមិនេះទៀតទៅ ។

ធានី ៖ ហ្នឹងហើយ ចង់និយាយថា តាំងពីមីងធ្វើមកមីងគិតមើលធ្វើបានប៉ុន្មានដង ហើយគិតថា ប៉ុន្មានឆ្នាំបានមីងធ្វើហើយ?

ទាវ ៖ ខ្ញុំទៅធ្វើទំនប់នោះ ខ្ញុំទៅធ្វើតែ៣ខែទេ ។

ធានី ៖ ធ្វើ៣ខែ តែម្តងនឹងទេ?

ទាវ ៖ ចា៎!

ធានី ៖ ហើយក្រោយមកទៀត លែងបានធ្វើទៅ?

ទាវ ៖ ដល់ក្រោយមកទៀត ខ្ញុំអត់បានទៅទៀតទេ ។

ធានី ៖ តែពេលដែលមីងធ្វើមានមនុស្សច្រើនទេ ដែលចូលរួមធ្វើ?

ទាវ ៖ មនុស្សរាប់ពាន់នាក់ ។

ធានី ៖ ដឹងមកពីណាខ្លះ?

ទាវ ៖ ដឹងមកពីណាខ្លះ តាមភូមិគ្រប់ភូមិទៅលើក តាមសង្កាត់គ្រប់សង្កាត់ ។

ធានី ៖ ដឹងមកច្រើន ហើយភាគច្រើនលាយគ្នា ហើយអ្នកស្លាប់ភាគច្រើន ជាអ្នកថ្មី មានជម្ងឺរាគ រុះអីទៅ?

ទាវ ៖ ចា៎! ជម្ងឺស្លាប់ទៅ ។

ធានី ៖ ចុះមីងដឹងថាអ្នកណាអ្នកគ្រប់គ្រងនៅទំនប់នឹង អ្នកគ្រប់គ្រងមេធំនៅទំនប់នឹង?

ធាវ ៈ ទេ! ខ្ញុំអត់ដឹង ដឹងតែគេថាតាវ៉ាល់ តាមោង ។

ធានី ៈ តាវ៉ាល់ តាមោង ជាអ្នកណា?

ធាវ ៈ មិនដឹងអ្នកណាទេ មិនដែលឃើញមុខផង ឮតែគេថា ខ្ញុំមិនដែលឃើញមុខផង ។ មិនដែលឮ មិនដែលឃើញមុខផង ចុះយើងប្រជាជនសម័យនោះទៅដឹង គេឲ្យទៅលើកៗក៏ទៅៗ មិនបានជាបែងចែកចេះចុះអី ។ គ្រាន់គេហៅទំនប់តាវ៉ាល់ៗ ចេះទៅលើកនឹងគេទៅ ដឹងតែប៉ុននឹង ចុះអត់ផងអីផង ត្រង់ណាទៅមានអារម្មណ៍គិត ។

ធានី ៈ គេហៅទំនប់តាវ៉ាល់?

ធាវ ៈ ចា៎! ទំនប់តាវ៉ាល់ ។

ធានី ៈ ចុះតាវ៉ាល់នឹងមកពីណាមីងដឹង?

ធាវ ៈ អត់ដឹងទេ ។

ធានី ៈ ហើយតាមោងនឹងអត់ដឹងដែរ?

ធាវ ៈ អត់ដឹង ។

ធានី ៈ អត់ដឹងថាគាត់ជាអ្នកណាទេ គ្រាន់ដឹងថាគេហៅជាទំនប់តាវ៉ាល់?

ធាវ ៈ អត់ដឹងថាគាត់ជាអ្នកណា គ្រាន់គេហៅទំនប់តាវ៉ាល់ ។

ធានី ៈ ទំនប់តាវ៉ាល់នឹងនៅណា?

ធាវ ៈ នៅត្រពាំងថ្មនឹងឯង ហៅទំនប់តាវ៉ាល់ៗ ។

ធានី ៈ ចុះម៉េចមីងដឹងថាអ្នកណាគេអ្នកបង្កើតទំនប់នឹង ឲ្យមានកសាងអីចឹង?

ធាវ ៈ អត់ដឹងទេ ស្រាប់តែគេឲ្យទៅលើក ។

ធានី ៈ ចុះមីងដឹងថាអ្នកណាគេអ្នកជួយ យើងត្រូវធ្វើនេះៗ អ្នកណាគេអ្នកប្រាប់?

ធាវ ៈ ប្រធានក្រុមគេម្នាក់ៗទៅ គេរើសឲ្យយើងលើកទៅ ។

ធានី ៈ គេបន្តគ្នា យើងអត់ដឹងដែរ?

ធាវ ៈ ចា៎!

ធានី ៈ ចុះអ្នកណាប្រធានតំបន់នៅនឹង ដឹងទេ?

ធាវ ៈ ខ្ញុំអត់ដឹងទេ ។

ធានី ៈ គណៈស្រុកអីក៏អត់ដឹង?

ធាវ ៈ អត់ដឹង ។

ធានី ៈ គណៈភូមិភាគក៏អត់ដឹង?

ទាវ ៖ ចា៎!

ធានី ៖ ចុះគណៈឃុំ?

ទាវ ៖ ឃុំព្រះនេត្រព្រះនឹង ។

ធានី ៖ គណៈឃុំដែលមើងរស់នៅនឹង កាលសម័យខ្មែរក្រហម?

ទាវ ៖ មុនដំបូងតាក្រក់ ។

ធានី ៖ តាក្រក់នឹងជាអ្នកណា?

ទាវ ៖ កាលនោះមិនមែននៅភូមិនេះទេ ភូមិគាត់មិនដឹងនៅខាងណា ខ្ញុំមិនដឹងផង ។

ធានី ៖ តែគាត់ធ្វើជាអីគេ?

ទាវ ៖ ធ្វើប្រធានឃុំ ប្រធានសង្កាត់ ។

ធានី ៖ ប្រធានសង្កាត់នៅណា?

ទាវ ៖ សង្កាត់ព្រះនេត្រព្រះ ។

ធានី ៖ ហើយយ៉ាងម៉េចទៀត?

ទាវ ៖ ប៉ុនសព្វថ្ងៃគាត់បាត់ខ្លួនហើយ មិនដឹងទៅខាងណា ។

ធានី ៖ ហើយតាក្រក់ធ្វើប្រធានសង្កាត់ព្រះនេត្រព្រះ អ្នកចាត់ចែងមើងឲ្យទៅណាទៅណែនឹង ឬក៏ម៉េច?

ទាវ ៖ គាត់អ្នកចាត់ចែងប្រធានភូមិទៅ ប្រធានភូមិក៏គេចាត់ចែងទៅទៀត ។

ធានី ៖ ចុះប្រធានភូមិ មើងស្គាល់ឈ្មោះគាត់?

ទាវ ៖ ប្រធានភូមិឈ្មោះតាសាម៉ូន ប៉ុនគាត់ស្លាប់ហើយ ប៉ុនគាត់អត់មាននៅភូមិកំណើតនេះទេ គាត់នៅស្រុកដើង នៅស្រុកព្រៃកើតគេយកមកឲ្យកាន់នៅភូមិនេះ ។

ធានី ៖ នៅភូមិអីគេដឹងទេ?

ទាវ ៖ ភូមិព្រៃ ស្រុកព្រៃ ។

ធានី ៖ ភូមិព្រៃ ឃុំព្រៃ ស្រុកអីគេ?

ទាវ ៖ អត់ដឹងស្រុកអីទេ ស្រុកកំណើតគាត់នៅនោះ ខ្ញុំមិនដឹងទេ ។

ធានី ៖ ប៉ុនដឹងថានៅខេត្តនឹងដែរ?

ទាវ ៖ ចា៎!

ធានី ៖ តាសាម៉ូនជាប្រធានភូមិ?

ទាវ ៖ ចា៎!

ធានី ៖ ហើយ និ ជាប្រធានមេកងមីង?

ទាវ ៖ ចា៎!

ធានី ៖ ចុះពេលដែលមីងធ្វើនៅនឹងមានការលំបាកអីទេ?

ទាវ ៖ អូ! លំបាកណាស់ ។

ធានី ៖ លំបាកយ៉ាងម៉េចទៅ?

ទាវ ៖ លំបាកត្រង់ហូបមិនគ្រប់គ្រាន់ ហើយទឹកអត់ដឹកគ្រប់គ្រាន់ទៀត ស្លៀកពាក់ក៏អត់មានគ្រប់គ្រាន់ មានតែយ៉ាប់ៗ ដូចថាបើកសំពត់តេរ៉េឡែតឲ្យយើងចេះទៅ យើងកន្ទេងខែយើងផ្ទុតទឹកម្ដង ម៉ាអាទិត្យផ្ទុតទឹកម្ដង តែឡើងតាម តែវានៅតាមសាច់ចេះ យើងអេះចេញតែយើងមកសៗចេញមកៗ ហើយទាល់លើកខែរត្រៀមម៉ាអាទិត្យចេះឲ្យរួច លើកទៅម៉ាខែរត្រៀមចេះទៅ បានទឹកមុជម្ដងទៀតៗ

ធានី ៖ ហើយចឹងរស់យ៉ាងម៉េចទៅ បើតែម៉្ងៗ ហើយហូបចុក?

ទាវ ៖ ចា៎ៗ តែ ហើយហូបចុកមិនគ្រប់គ្រាន់ ហើយដេកក៏អត់ស្រួលបានទេ វារមាស់ៗ ហើយប្រជាជនទៅពីភូមិផាត់ៗចេះ មកវិញស្គម ខ្ញុំចេះមកវិញម៉ែឪមើលអត់ស្គាល់ទេៗ

ធានី ៖ ហើយម៉ែឪគាត់អត់អីវិញ?

ទាវ ៖ ម៉ែឪនៅភូមិ គាត់អត់ដែរ ប៉ុនៗ

ធានី ៖ ស្គម?

ទាវ ៖ ប៉ុនស្គម ចុះគាត់ហូបតែបបរទេៗ

ធានី ៖ តែគ្រាន់គាត់អាចមានទឹកអីផ្ទុតចឹង?

ទាវ ៖ ចា៎! គាត់មានទឹកអីហូបគ្រប់គ្រាន់ៗ

ធានី ៖ ចឹងមីងមានអារម្មណ៍ម៉េចដែរទៅ កាលមុនដំបូងចង់ទៅកងចល័ត ដល់ពេលកងចល័តយ៉ាប់ចឹងចាញ់អ្នកនៅភូមិផង?

ទាវ ៖ ទេ! ចាញ់តើ ដូចថាយើងទៅហើយ គេគំរូវឲ្យទៅហើយ ក៏ទៅៗ ដឹងឈឺចិត្តៗហើយប៉ុន មិនដឹងធ្វើម៉េច សុំម៉ាខ្លួនរស់ទៅៗ

ធានី ៖ ចឹងពេលនៅនឹង មីងខស្សរាហ៍ឃើញគេបាត់ខ្លួនអត់នៅជាមួយកងមីង?

ទាវ ៖ អត់ទេៗ

ធានី ៖ អត់មានទេ នៅជុំគ្នាទាំងអស់?

ទាវ ៖ ចា៎!

ធានី ៖ អត់បាត់?

ទាវ ៖ ចាំ! អត់បាត់ទេ ។

ធានី ៖ សុទ្ធតែកងយើងអ្នកចាស់?

ទាវ ៖ កងចាស់ កងថ្មីលាយគ្នា ប៉ុន្មាកងយើងធ្វើការអត់មានអ្នកណាបាត់ អត់មានអ្នកណាអីទេ ។

ធានី ៖ ចុះកាលពេលមីងនៅភូមិនឹង អ្នកថ្មីជម្លៀសមកដល់ភូមិនេះនៅ?

ទាវ ៖ នៅតើ ភូមិនេះក៏នៅៗដក់ពរក៏នៅ ។

ធានី ៖ ហើយមកនៅជុំជាមួយមីងដែរ?

ទាវ ៖ ចាំ!

ធានី ៖ ហើយពួកគាត់មកពីណាខ្លះ អ្នកថ្មីនឹង?

ទាវ ៖ ពុំថាមកមិនដឹងនៅស្រុកណាទេ ស្រាប់តែមកពីភ្នំពេញៗ ។

ធានី ៖ មកពីភ្នំពេញច្រើន?

ទាវ ៖ ចាំ!

ធានី ៖ ហើយយ៉ាងម៉េចដែរ អ្នកអស់នឹង ធ្វើការដូចយើងទេ ចំណាប់ចំនួន?

ទាវ ៖ ធ្វើការដូចយើងដែរតើ ប៉ុន្តដូចថាគាត់មិនសូវមានការតស៊ូទេ គាត់ដូចថាមានហូបចុកគ្រប់គ្រាន់ មិនដូចស្រុកស្រែយើងដែលថាហូបនេះទៅចេះតែធ្វើ គាត់នោះរៀងទន់ជ្រាយដែរច្រើនស្លាប់តែអ្នកមកពីខាងនឹងឯង ។

ធានី ៖ ច្រើនទេមីង ដែលមីងស្គាល់ មីងធ្លាប់រាប់អានជាមួយគាត់ ឬក៏យ៉ាងម៉េចដឹងពីគាត់?

ទាវ ៖ ខ្ញុំមានដែរតើ អ្នកមកពី ថ្ងៃមុនខែឆ្នាំមុន គាត់មកលេងស្រុកខ្ញុំដែរតើ មកពីកំពង់ចាម បើក ឡានមកលេង ។

ធានី ៖ ចឹងពេលដែលមីងនៅកងចល័តនឹង លើកតែពាខែ មីងទៅណាទៀតទៅ?

ទាវ ៖ មកលើកទំនប់ព្រៃមាន់យើង ។

ធានី ៖ លើកទំនប់ព្រៃមាន់?

ទាវ ៖ ចាំ!

ធានី ៖ ចឹងនៅត្រពាំងថ្មហើយ បានលើកទំនប់ព្រៃមាន់? លើកទំនប់ព្រៃមាន់ហើយធ្វើអីទៀត?

ទាវ ៖ គេជម្លៀសមកឲ្យនៅអូរអណ្តូង លើកក្រវាត់ភ្លឺស្រែអូរអណ្តូង ។

ធានី ៖ ម៉េចទៀតទៅ?

ទាវ ៖	ហើយបានមកលើកយើងអាទំនប់កំបោរនេះ ។

ធានី ៖	ចុះពេលដែលមីងលើកទំនប់ចឹងម៉េចដែរ គេឯអីគ្រប់គ្រាន់?

ទាវ ៖	និយាយរឿងហូបគ្រប់គ្រាន់ គ្មានអ្នកណាគ្រប់គ្រាន់ ។

ធានី ៖	គេឯអី?

ទាវ ៖	គេឯមិនបានគ្រប់គ្រាន់ទេ តែម៉ោង១ជិតភ្លឺ គេដាស់លើកទៀត ។

ធានី ៖	ចុះគេឯស្មានណា?

ទាវ ៖	តែថ្ងៃណាទៅគេឯបាន២-៣ម៉ោងទៅ ថ្ងៃណាគេបាន២-៣ម៉ោង ថ្ងៃណាគេឯបានម៉ោម៉ោង ។

ធានី ៖	ហើយចឹងធ្វើការម៉េចកើត បើលើកទំនប់ហត់ ហើយម្នាក់បាន?

ទាវ ៖	ចុះបើយើងដាច់ខាតហើយ ធ្វើតាមគេ ។

ធានី ៖	ប៉ុន្តែបើថាមីងអីអាចទ្រាំទ្រូច?

ទាវ ៖	បេះតែខំទៅ ខ្លាចគេវ៉ៃចោល ។

ធានី ៖	ទោះជាអត់ងងុយម៉េច ក៏ទៅបាន?

ទាវ ៖	ចាំ! អត់ងងុយ បេះទ្រាំទៅ លើកទំនប់ពីស្រែះទៅកំបោរ លើកពីស្រែះមកព្រះនេត្រព្រះ លើកពីប៉ោយសំរោងទៅស្រែះទៀត លើកកម្លាំងទាំងអស់ អត់បាននៅភូមិទេ ក្នុង៣ឆ្នាំ ។

ធានី ៖	ហើយមីងយល់ថាម៉េចដែរ ពេលដែលមីងលើកធ្វើការ ជាពិសេសនៅត្រពាំងថ្ម ។ ការពេលដែលមីងលើកនឹងមានឡើងតួឡើងអីអត់ លើកឡើងភ្នំ ឬក៏អត់នៅត្រឹមរាបៗ ។

ទាវ ៖	លើកឡើងតើ លើកដល់ខ្នងលើ ។

ធានី ៖	កំពស់ប៉ុន្មាន?

ទាវ ៖	កំពស់៥ម៉ែត្រ ។

ធានី ៖	កំពស់៥ម៉ែត្រ ដែលមីងលើកនឹង?

ទាវ ៖	ចាំ!

ធានី ៖	តែអាទំនប់នឹងវែងទែន កំពស់វាប៉ុន្មាន មីងដឹង?

ទាវ ៖	កំពស់វា៥ម៉ែត្រនឹង បាតក្រោមវា១៥ម៉ែត្រ ។

ធានី ៖	បាតក្រោមម៉េច?

ទាវ ៖	ជើងវា ។

ធានី ៖	ជើងវាទេនឹង ១៥ម៉ែត្រ?

ទាវ :	ចា៎! ១៥ម៉ែត្រ ប៉ុនខ្ពស់លើតែ៥ម៉ែត្រ ។

ធានី :	ខ្ពស់លើតែ៥ម៉ែត្រម៉េច?

ទាវ :	អាខ្ពស់ថ្នល់យើងនេះតែ៥ម៉ែត្រទេ ។

ធានី :	ពីនេះទេវឡើងចេះ ៥ម៉ែត្រ?

ទាវ :	ទេវឡើង៥ម៉ែត្រ ។

ធានី :	តែដល់ពេល អានឹងដើងទំនប់មែនទេ?

ទាវ :	ចា៎! បាតក្រោមចេះ១៥ ។

ធានី :	បាតក្រោមនេះ បាតក្រោមដើងទំនប់ទេ ដល់ពេលទំនប់តែម្តងវាមានប្រវែងប៉ុន្មាន?

ទាវ :	ដល់បាតលើចេះ វាឃើញ៥ម៉ែត្រ ។

ធានី :	ប្រវែងប៉ុន្មានដឹងទេ?

ទាវ :	ខ្ញុំអត់ដឹងទេ ប្រវែងប៉ុន្មានៗអត់ដឹង ។

ធានី :	គ្រាន់ដឹងថាយើងលើកដីងប៉ុននឹង?

ទាវ :	ចា៎! គ្រាន់តែថាលើក ។

ធានី :	តែអត់ដឹងទំនប់នឹង គេសម្ពោធន៍ពេលណាទេ?

ទាវ :	ខ្ញុំៗបានទៅប្រជុំគេ យកទៅសម្ពោធន៍ដែលលើកទំនប់រួច គេនាំគ្នាទៅសម្ពោធន៍នៅស្ពាន ទី១នោះ គេសម្ពោធន៍នៅ៧មករានោះ ។ ប្រជាជនច្រើនណាស់ រាប់ពាន់នាក់ ។

ធានី :	សម្ពោធន៍នៅថ្ងៃ៧មករា?

ទាវ :	ចា៎!

ធានី :	៧មករាឆ្នាំប៉ុន្មាន?

ទាវ :	មិនដឹងឆ្នាំប៉ុន្មានទេ ភ្លេចអស់មែន ។

ធានី :	មិនមែន៧មករា៧៩?

ទាវ :	ដឹងគេហៅម៉េចទេ ខ្ញុំភ្លេចអស់ហើយ ហៅយ៉ាងណាទេ ។

ធានី :	តែដឹងថាខែមករា?

ទាវ :	វាមិនសូវចាំទេ កាលនោះមិនមែន៧មករាទេ កាលនោះគេហៅស្អីត្រង់ណាទេ គេហៅប្រជុំ ហៅម៉េចទេ ខ្ញុំភ្លេចអស់ហើយ កាលនោះខ្ញុំអត់បានរៀនអត់បានចាំ ។

ធានី :	តែមីងបានចូលរួមសម្ពោធន៍នឹងដែរ?

ទាវ :	ចូលតើប៉ុនភ្លេចអស់ហើយ ។

ធានី :	ពុអ្នកណាគេអ្នកមកបើកកម្មវិធីសម្ពោធន៍នឹង មីងដឹងទេ?

ទាវ :	អត់ដឹងទេ វាដឹងប៉ុនយូរទៅវាភ្លេចអស់ហើយ មិនបានជាចាំណា គ្រាន់តែដឹងថាទៅ គេទៅប្រជុំគេលេងសិល្បៈលេងឲ្យយើងមើល ។

ធានី :	សិល្បៈគេងលេងឲ្យយើងមើលម៉េច?

ទាវ :	លេងច្រៀងបទខ្មែរក្រហមនេះឯង ។

ធានី :	គេមកលេងផ្ទាល់?

ទាវ :	គេមកលេងផ្ទាល់ គេមកលេងឲ្យយើងមើល ។

ធានី :	ហើយម៉េចទៀត?

ទាវ :	ទៅម៉ាទន្លេធំចេះទៅ គេប្រជុំឲ្យយើងមើលកណ្ដាលថ្ងៃនេះទៅ ។

ធានី :	នៅកន្លែងណា?

ទាវ :	នៅកន្លែងស្ពានទី១ ។

ធានី :	ទទួលអ្នកអស់នឹងបានដែរ ព្រោះអីកាលនឹងទំនប់នឹង កាលនឹងមានទឹកនៅ?

ទាវ :	នៅអត់ទាន់មានទឹកទេ ។

ធានី :	គេអត់ទាន់បើកទឹកចូល?

ទាវ :	អត់ទាន់មាន ។

ធានី :	ប៉ុន្តែគេសម្ពោធន៍?

ទាវ :	ចាំ! សម័យអាពតណា ។

ធានី :	ចឹងទំនប់នឹងធ្វើហើយភ្លាម អត់ទាន់មានទឹក ហើយគេសម្ពោធន៍ទៅ?

ទាវ :	អត់មានទឹកទេ ។

ធានី :	អត់មានទឹកចឹងធ្វើម៉េចទៅ?

ទាវ :	ចុះទឹកនោះអ្នកលើករួចគេមិនទាន់បើកទឹកណា ។

ធានី :	ហើយដល់លើករួចហើយ គេសម្ពោធន៍នៅក្នុងទំនប់នឹង គេធ្វើម៉េចទៀតទៅ?

ទាវ :	អត់ដឹងធ្វើម៉េចទេ ។

ធានី :	ម៉េចបានមានទឹក?

ទាវ :	គេបិទស្ពានទៅវាជាប់ទឹកទៅ ។

ធានី :	ដល់ពេលគេសម្ពោធន៍ហើយ គេបើកទឹកវិញអត់?

ទាវ :	បើកទឹកទៅ បានឲ្យប្រជាជនធ្វើស្រែប្រាំង ធ្វើស្រែវស្សាទៅ ។

ធានី : ចឹងពេលសម្ពោធន៍នឹង គឺអត់មានទឹកទេនៅក្នុងទំនប់នឹង?

ទាវ : អត់ទេ ។

ធានី : ដល់ពេលសម្ពោធន៍ហើយ បានគេបើកស្ពានឲ្យ?

ទាវ : ដល់ខែវស្សាបានមានទឹក ។

ធានី : ដល់ខែវស្សាបានមានទឹក?

ទាវ : ចា៎!

ធានី : ចឹងកាលពេលគេសម្ពោធន៍នឹង ខែប្រាំង?

ទាវ : ចា៎! ដល់ឥឡូវនេះ សម្ពោធន៍ ដល់គេបិទស្ពានរួចបានមានទឹក ។ បានទឹកជាប់ ។

ធានី : ចឹងកាលពេលសម្ពោធន៍ អត់ទាន់បិទស្ពានទេ?

ទាវ : អត់ទាន់បិទស្ពាន ។

ធានី : តែគេសម្ពោធន៍ ឬគេមកលេងសិល្បៈឲ្យយើងមើលទេ?

ទាវ : ទេ! ពុតែគេថាសម្ពោធន៍ៗ មិនដឹងថាយ៉ាងម៉េចទេ កាលនឹងនៅតូចដែរនឹង ។

ធានី : ចឹងកាលនឹងគេថាសម្ពោធន៍ៗដែរ?

ទាវ : ចា៎! ដែលគេថាសម្ពោធន៍ ។

ធានី : ប៉ុន្តែ មីងថាឃើញខ្មែរគ្រៀម អាពខ្មែរនឹង ក្រែងមានស្ពានមួយៗហើយៗ ប៉ុន្តែវាអត់ទាន់បិទទឹក អត់បិទស្ពានម៉េច?

ទាវ : ស្ពានមុនៗ ស្ពានគេដាក់លូ ដល់អាស្ពានទី១នេះ បានស្ពានគេដាក់បិទ ស្ពានធំ ស្ពានត្រពាំង ថ្មនឹង ។

ធានី : គ្រាន់តែចង់សួរមីង ព្រោះមីងថាគេបិទទឹកម៉េចនោះ?

ទាវ : បិទទឹកស្ពានមួយនោះឯង ។

ធានី : ប៉ុន្តែដោយសារការធ្វើហើយភ្លាម គឺអត់ទាន់មានទឹកចូលទេ?

ទាវ : ចា៎!

ធានី : ដល់ពេលខែវស្សាមកភ្លៀងមកបានដក់ទឹកម្ដងតិចៗទៅ?

ទាវ : ចា៎! បានមានទឹក ពេលទឹកជំនន់មកអត់មានទឹកគេបិទទឹកជាប់ ។

ធានី : បានគេបិទទឹកឲ្យវាមានពេលហើយចាំគេបើកទឹកតិចម្ដងៗ?

ទាវ : គេបិទជាប់ចេះទៅ បានមានទឹករហូត មានត្រីមានអីកោះកុំនៅ ។

ធានី : ចឹងកាលពេលមុនដំបូងមីងអត់ដឹងថាអ្នកណាគេអ្នកមកសម្ពោធន៍ទេ?

ទាវ ៖ អត់ដឹង ។

ធានី ៖ ចុះតាវ៉ាល់តាអី?

ទាវ ៖ ឮតែគេថា តែថាយើងមិនដែលស្គាល់មុខផង ។

ធានី ៖ គ្រាន់ឮគេថា?

ទាវ ៖ ឮតែគេថា មិនដែលស្គាល់មុខយ៉ាងម៉េច គ្រាន់តែគេថាទៅលើកទំនប់តាវ៉ាល់ ទំនប់តាមោង ប៉ុននោះឯង គ្រាន់ឮតាវ៉ាល់មិនដឹងមុខយ៉ាងណាបើខ្ញុំអត់ដែលឃើញ ។

ធានី ៖ អត់ដែលឃើញ?

ទាវ ៖ ចា៎!

ធានី ៖ មីងមានអារម្មណ៍ម៉េចដែរ ពេលដែលមីងមកដល់ឥឡូវហើយ មីងធ្លាប់ទៅលេងត្រពាំងថ្ម?

ទាវ ៖ ទៅតើ ។

ធានី ៖ យល់ថាម៉េចដែរកន្លែងនឹង មីងធ្លាប់លើកទំនប់លើកអីចឹង?

ទាវ ៖ ទេ! ពេលទៅឃើញចេះ នឹកឃើញរឿងដើមកំសត់ដែរ កំសត់ថាខ្លួនពិបាកវេទនា ដោយសារអាងត្រពាំងថ្ម ដល់បានសង់ហើយ គេរៀបចំស្អាត គេសប្បាយរីករាយនឹងគេ ។

ធានី ៖ សប្បាយយ៉ាងម៉េច?

ទាវ ៖ សប្បាយឃើញទឹក ឃើញអីមានប្រជាជនធ្វើស្រែបានស៊ី ។

ធានី ៖ បានទឹកអាងត្រពាំងថ្មនឹង?

ទាវ ៖ ចា៎!

ធានី ៖ ប៉ុន្តែមីងដែរគិត ចុះមីងធ្លាប់ប្រាប់ថា នៅកន្លែងតាមស្ពាននីមួយៗ មានមនុស្សរកប់ មីងខ្លាចអត់?

ទាវ ៖ ទេ! គ្មានអារម្មណ៍ខ្លាចផង សម័យនឹងអត់មានអារម្មណ៍ខ្លាចខ្មោចផង សម័យនោះអត់ដឹងថា ខ្លាចខ្មោចផង ។

ធានី ៖ អត់ទេ ចង់ដឹងថាដូចឥឡូវអី?

ទាវ ៖ ឥឡូវក៏មិនខ្លាច តែខ្ញុំមិនសូវបានទៅទេ ឥឡូវនេះ ។

ធានី ៖ តែដែលគិតរឿងនឹង?

ទាវ ៖ អត់ដែលគិត ។

ធានី ៖ ចុះមីងដែលធ្លាប់ឮរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

ទាវ ៖ អត់ ។

ធានី ៖ អត់ដែលឮថាគេមានតុលាការកាត់ទោសមេដឹកនាំធំៗ?

ទាវ ៖ អត់ដែលឮៗតែគេកាត់ទោសៗ បែកតាមសៀវភៅ ។

ធានី ៖ កាត់ទោសអ្នកណាគេដឹងទេ ។

ទាវ ៖ ចែងថា កាត់ទោសហើយ លោកតាឌុច ។

ធានី ៖ ចាំ! ឥឡូវបន្ទាប់ពីតាឌុច កាត់ចប់ទៅ គេកាត់ទោស៤នាក់បន្ថែមទៀត ។ ៤នាក់នឹងជាមេដឹកនាំជាន់ខ្ពស់ដែរ ទី១អៀង សារី គាត់រដ្ឋមន្ត្រីក្រសួងការបរទេស, អៀង ធីរិទ្ធ ប្រពន្ធរបស់គាត់នឹង ដែលគាត់ធ្វើខាងក្រសួងសង្គមកិច្ច ខាងថ្នាំពេទ្យខាងអី, ដល់ពេលមួយទៀតខៀវ សំផន គាត់ជាប្រមុខរដ្ឋកាលមុន ដូចស្តេចយើងឥឡូវចឹង, ហើយដល់មួយទៀតគឺនួន ជា គាត់នៅខាងក្រសួងរដ្ឋសភា ។ ចំពោះមីងផ្ទាល់យល់ថាម៉េចដែរ ចំពោះការកាត់ទោសគាត់ទាំង៤នាក់នឹង?

ទាវ ៖ ដល់ខ្ញុំនៅឆ្ងាយ ខ្ញុំមិនដែលដឹងមានអារម្មណ៍ថា បើគាត់ខុស ក៏កាត់ទោសគាត់ ។

ធានី ៖ គិតតែប៉ុននឹង?

ទាវ ៖ ចាំ! គិតប៉ុននឹងឯង ។

ធានី ៖ ចុះមីងអត់គិតថា ពួកគាត់ដែលបណ្តោយឲ្យមីងធ្វើការអស់កម្លាំង ធ្វើការលើកទំនប់លើកអីគ្មានពេលសម្រាក បែកម៉ែបែកឪ ដែលគិតចឹង?

ទាវ ៖ គិតដែរ គិតថាបែកម៉ែឪ មានអារម្មណ៍គិតថាឈឺចាប់ដែរ ឈឺចាប់ដូចថាមិនដែលបានជួបម៉ែឪបានសុខសាន្ត នៅដេកជាមួយគ្នា ឲ្យឃើញមុខម៉ែឪ ។ ឈឺចាប់ រំដោះបានប៉ុននេះ ក៏នៅតែឈឺចាប់ៗ ។

ធានី ៖ ចុះដល់ពេលគេកាត់ទោសអ្នកអស់នឹងចឹង មីងនៅមានអារម្មណ៍ឈឺចាប់ទៀត ឬយ៉ាងម៉េច?

ទាវ ៖ នៅមានឈឺចាប់តែចឹង ។

ធានី ៖ មីងគិតថាការមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មានប្រយោជន៍អីអត់ទេ យើងបង្កើតឲ្យមានចឹង? កាត់ទោសអ្នកដែលមេដឹកនាំធំៗ ដែលបណ្តោយឲ្យមានរបបនឹងហើយបណ្តោយឲ្យមីងឃ្លាតម៉ែ ឃ្លាតឪ ។ មីងគិតថាមានប្រយោជន៍អត់ ការកាត់ទោសដូចមីងឮថាកាត់ទោសឌុច តើគិតថាការកាត់ទោសឌុចមានប្រយោជន៍អត់?

ទាវ ៖ ទេ! មានប្រយោជន៍ខាងសង្គមដែរតើ ។

ធានី ៖ ប្រយោជន៍យ៉ាងម៉េច?

ទាវ ៖ ប្រយោជន៍ត្រង់ថា ដែលនាំប្រទេសជាតិ ក្បត់ប្រទេសជាតិលិចលង់ ពិបាកវេទនា ហូបចុក មិនឆ្អែត ។

ធានី ៖ អត់អស់នឹង?

ទាវ ៖ ចាំ!

ធានី ៖ អ្នកអស់នឹងនាំឲ្យប្រទេសជាតិលិចលង់?

ទាវ ៖ ចាំ!

ធានី ៖ ឲ្យប្រជាជនពិបាកវេទនា?

ទាវ ៖ វេទនា អត់មានសាសនា បែកប្រពន្ធបែកកូន មានការកាប់សម្លាប់ ខុសឆ្គងតិចតួចវ៉ៃគ្នាចោល អត់មានគ្រាប្រណី ថាជាតិខ្មែរដូចគ្នាអត់ ។

ធានី ៖ ចុះមីងដែលឮឈ្មោះយាយចែម?

ទាវ ៖ ឮតើ ខ្ញុំលើកទំនប់គាត់ដែរតើ ។

ធានី ៖ លើកទំនប់គាត់ដែរ?

ទាវ ៖ ចាំ! ទំនប់គេហៅនៅអូរលាភៗ នោះទំនប់យាយចែមដែរតើ ។

ធានី ៖ ទំនប់អូរលាភ ទំនប់យាយចែម?

ទាវ ៖ ចាំ!

ធានី ៖ មីងស្គាល់គាត់អត់?

ទាវ ៖ អត់ស្គាល់ទេ ប៉ុនគេថាទំនប់យាយចែមៗ ។

ធានី ៖ គេហៅយាយចែមៗ?

ទាវ ៖ ចាំ!

ធានី ៖ ម៉េចចឹង បានគេហៅទំនប់នឹង ទំនប់យាយចែម?

ទាវ ៖ មិនដឹងគេហៅម៉េច គេហៅចឹងឯង ។

ធានី ៖ ចឹងមីងដឹងថាយាយចែមនឹងជាអ្នកណា?

ទាវ ៖ យាយចែម ជាមនុស្សស្រី ។

ធានី ៖ ហើយគាត់ជាអ្នកណា?

ទាវ ៖ មិនដឹងថាអ្នកណាទេ បើហៅយាយចែមៗ ។

ធានី ៖ អត់ដឹងថាគាត់មានឋានៈជាអី?

ទាវ ៖ អត់ដឹងទេ ។

ធានី : តែដឹងថាគាត់?

ទាវ : ចា៎!

ធានី : ដឹងថាយាយថែម?

ទាវ : ចា៎! ពួកខ្ញុំនៅក្មេងខ្ញុំម៉េចដឹង ។

ធានី : អត់ចាប់អារម្មណ៍?

ទាវ : អត់ចាប់អារម្មណ៍ ។

ធានី : ចឹងមីងមានអីចង់បន្ថែមទៀតទេ នូវអ្វីដែលខ្ញុំអត់បានសួរ ចង់សួរនាំអី ឬសំណូមពរអី?

ទាវ : គ្មានអីសួរទៀតផង គ្មានអីត្រូវនិយាយទៀតផង ។

ធានី : អត់មានអីនិយាយមីង?

ទាវ : ចា៎!

ធានី : ចា៎! ចឹងអរគុណមីងច្រើន ។

ទាវ : ចា៎!

«ចប់»